ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៤៥៤២ អយក.ជាវ

ថ្ងៃ សុក្រ ៦រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០

## ជម្រាបមក
## លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

**កម្មវត្ថុៈ** សំណើអញ្ជើញសមាសភាពចូលរួមវគ្គសិក្ខាសាលាស្តីពី **"នីតិវិធីនិងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ"** ក្នុងឆ្នាំ២០២០។

**យោងៈ** លិខិតលេខ ៨០១៥ សហវ.អថ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រីប្រធាន** ជ្រាបថាៈ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើបច្ចុប្បន្នភាពដោយបន្ថែមមុខងារប្រតិបត្តិការថ្មីមួយចំនួនឱ្យកាន់តែមានលក្ខណៈល្អប្រសើរនិងស្វ័យប្រវត្តិ ទៅលើប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រោងថវិកានិងរបាយការណ៍ហិរញ្ញវត្ថុ **(SOF)** ព្រមទាំងឱ្យស្របតាមស្មារតីនៃលិខិតលេខ ៨០១៥ សហវ.អថ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដោយហេតុនេះ ក្រសួងនឹងរៀបចំវគ្គសិក្ខាសាលាស្តីពី **"នីតិវិធីនិងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ"** នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត ក្នុងគោលបំណងពង្រឹងសមត្ថភាពជូនថ្នាក់ដឹកនាំអង្គភាព និងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុនិង ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រោងថវិកានិងរបាយការណ៍ហិរញ្ញវត្ថុ ក្នុងទិសដៅឆ្លើយតបទៅនឹងចក្ខុវិស័យនៃកំណែទម្រង់វិស័យអប់រំបច្ចុប្បន្នដែលផ្តោតទៅលើការអប់រំបែបឌីជីថល(Digital Education)។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវរៀបចំវគ្គសិក្ខាសាលាឱ្យទាន់ពេលវេលាអនុវត្តក្នុងពេល ដ៏ខ្លីខាងមុខនេះ។

អាស្រ័យហេតុនេះសូម **លោក លោកស្រីប្រធាន** ចាត់តាំងសមាសភាពចូលរួមតាមកាលបរិច្ឆេទ ទីកន្លែង និងសមាសភាពចូលរួមដូចមានក្នុងតារាងជូនភ្ជាប់ដោយត្រូវធ្វើលិខិតឧទ្ទេសនាមរួចផ្ញើជូននាយកដ្ឋានហិរញ្ញវត្ថុឱ្យបានមុន០៥(ប្រាំ)ថ្ងៃ នៃការបើកវគ្គសិក្ខាសាលា។

ទំព័រទី ១/២

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**បញ្ជាក់៖**

- សូមភ្ជាប់មកជាមួយនូវកុំព្យូទ័រយួរដៃ (Laptop) សម្រាប់ការអនុវត្តផ្ទាល់ជាមួយក្រុមការងារ
- វគ្គសិក្ខាសាលានេះប្រើប្រាស់ថវិកាឆ្នាំ២០២០ របស់អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុ។

សូម **លោក លោកស្រីប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**រដ្ឋលេខាធិការ**

**ពិត_ចំណាន**

**ចម្លងជូន៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-កាលប្បវត្តិ
-ឯកសារនាយកដ្ឋានហិរញ្ញវត្ថុ